# **ដំណឹងជ្រើសរើសបុគ្គលិក**

**( អ្នកទទួលភ្ញៀវ/បេឡាករ )**

អង្គការម៉ារីស្តូបអន្តរជាតិកម្ពុជា គឺជាអង្គការអន្តរជាតិមួយដែលផ្តល់សេវាថែទាំសុខភាពបន្តពូជ, ពន្យារកំណើត និងសេវារំលូតកូនប្រកបដោយសុវត្ថិភាពដល់ស្ត្រី។ សេវាកម្មដែលពួកយើងផ្តល់ជូន ផ្តល់ឱ្យស្ត្រីនូវសិទ្ធិក្នុងការជ្រើសរើសនៅពេលដែលគាត់មានគ៌ភ ដើម្បីឱ្យគាត់មានសេរីភាពក្នុងការបន្តផែនការ និងសម្រេចក្តីសុបិន្តរបស់គាត់ និងគ្រួសារគាត់។ ចក្ខុវិស័យរបស់យើងគឺ **ពិភពលោកមួយដែលគ្រប់កំណើតទាំងអស់សុទ្ធតែជាការចង់បាន** ហើយបេសកកម្មរបស់យើងគឺដើម្បីធានានូវសិទ្ធិរបស់បុគ្គល: **មានកូនតាមប្រាថ្នាមិនមែនតាមការចៃដន្យ**។ អង្គការម៉ារីស្តូបអន្តរជាតិកម្ពុជាត្រូវការជ្រើសរើសបុគ្គលិក **០១ រូប** សម្រាប់បំពេញមុខតំណែងដូចខាងក្រោម:

| | |
|---|---|
| មុខតំណែង | **អ្នកទទួលភ្ញៀវ/បេឡាករ** |
| ទីតាំងបម្រើការងារ | **គ្លីនិកអង្គការម៉ារីស្តូប សែន សុខ (ភ្នំពេញ)** |

| **ភារកិច្ចចំបង និងការទទួលខុសត្រូវ** | **លក្ខណៈសម្បត្តិរបស់បេក្ខជន** |
|---|---|
| • ស្វាគមន៍គ្រប់អតិថិជនដែលអញ្ជើញមកគ្លីនិកដោយរួសរាយនិងមិនរើសអើង។<br>• ផ្តល់សេវាជូនអតិថិជនប្រកបដោយគុណភាពគ្រប់ពេលវេលា ប្រកបដោយវិជ្ជាជីវៈ និងមានសណ្តាប់ធ្នាប់។<br>• រៀបចំគ្លីនិកអោយបានស្អាត និងរៀបចំសម្ភារៈនិងឧបករណ៍ទាំងអស់អោយមានសណ្តាប់ធ្នាប់។<br>• ចែករំលែកសារ/ព័ត៌មានពីទីស្នាក់ការកណ្តាលដល់បុគ្គលិកនៅគ្លីនិក។<br>• បញ្ចូលទិន្នន័យរបស់អតិថិជនទៅក្នុងប្រព័ន្ធ CLIC ប្រចាំថ្ងៃ។<br>• ទាញយករបាយការណ៍ដែលពាក់ព័ន្ធពី CLIC ជូនទៅប្រធានគ្លីនិក និង/ឬទីស្នាក់ការកណ្តាល។<br>• ពិនិត្យមើលវេជ្ជបញ្ជារបស់អតិថិជននីមួយៗនិងប្រៀបធៀបជាមួយនឹងកំណត់ត្រានៅក្នុង CLIC ដើម្បីធានាភាពត្រឹមត្រូវនៃវេជ្ជបញ្ជាត្រូវបានផ្តល់ជូន។<br>• គ្រប់គ្រងសាច់ប្រាក់និងធានាថាមានសាច់ប្រាក់គ្រប់គ្រាន់នៅគ្លីនិកសម្រាប់ការចំណាយផ្សេងៗដែលកើតឡើងនៅក្នុងគ្លីនិក។<br>• ធានាថាសាច់ប្រាក់ទាំងអស់ត្រូវរក្សាទុកក្នុងទូនិងចាក់សោរទុកប្រកបដោយសុវត្ថិភាព និងតំកល់ជាទៀងទាត់ទៅក្នុងធនាគារ។<br>• ចេញបង្កាន់ដៃផ្លូវការជូនអតិថិជនសម្រាប់ការបង់ថ្លៃសេវាទាំងអស់។<br>• ធ្វើរបាយការណ៍ចំណូលចំណាយប្រចាំខែ។<br>• អនុវត្តភារកិច្ចផ្សេងៗទៀតទៅតាមការចាត់តាំងរបស់ប្រធានគ្លីនិក។ | • មានកម្រិតវប្បធម៌ សញ្ញាបត្រទុតិយភូមិឡើងទៅ<br>• រួសរាយរាក់ទាក់ក្នុងការទទួលភ្ញៀវ<br>• យល់ដឹងពីការគ្រប់គ្រងសកម្មភាពការងារប្រចាំថ្ងៃ<br>• មានជំនាញល្អក្នុងការទំនាក់ទំនងនិងស្តាប់<br>• អាចធ្វើការងារជាក្រុមបានល្អ ប្រកបដោយភាពស្មោះត្រង់<br>• អត្តចរិកល្អ ស្មោះត្រង់ និងមានសីលធម៌ល្អ |

**អង្គការម៉ារីស្តូបកម្ពុជាផ្តល់ជូននូវ ប្រាក់បៀវត្សដែលមានលក្ខណៈប្រកួតប្រជែង និងអត្ថប្រយោជន៍ផ្សេងៗជាច្រើន ដូចជាប្រាក់ឧបត្ថម្ភក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ធានារ៉ាប់រង២៤ម៉ោងលើសុខភាព(សម្រាប់បុគ្គលិកនិងគ្រួសារបុគ្គលិក) និងធានារ៉ាប់រងគ្រោះថ្នាក់ការងារ ការតម្លើងប្រាក់បៀវត្សប្រចាំឆ្នាំ ប្រាក់រង្វាន់លើកទឹកចិត្ត ប្រាក់សន្សំ និងអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀតតាមគោលការណ៍របស់អង្គការ។**

- ➢ បេក្ខជនបេក្ខនារីដែលមានចំណាប់អារម្មណ៍ចង់បម្រើការងារ សូមផ្ញើប្រវត្តិរូបសង្ខេបដែលមានភ្ជាប់ជាមួយអត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារចតចម្លង និងរូបថត ៤ គុណ ៦ មួយសន្លឹក ផ្ញើមកកាន់អង្គការម៉ារីស្តូបអន្តរជាតិកម្ពុជា ដែលមានអាសយដ្ឋាននៅមជ្ឈមណ្ឌលភ្នំពេញ អគារ F ជាន់ទី១ ឬនៅតាមគ្លីនិកម៉ារីស្តូបដែលនៅជិតលោកអ្នក។
- ➢ លេខទូរស័ព្ទទំនាក់ទំនង ០២៣ ៩៩៤ ០៨៣ /០៩៦ ៦៤០៨ ១១៨ ។
- ➢ អ៊ីមែល hrd@mariestopes.org.kh ។
- ➢ ឈប់ទទួលពាក្យ ថ្ងៃទី **១៥** ខែ **វិច្ឆិកា** ឆ្នាំ **២០២០**